# From the Editor

Busy Christians have so many things to think about—and all are important! Budgets, plans, meetings with government officials, sermons, discipleship, church discipline. So we push lesser matters aside.

But sometimes in the crush to get things done we forget what truly is important.

It happened in Jesus' day. He met crowds who hung on his words, spies trying to trap him in his speech, lame and blind who cried for his healing touch. This is important stuff! So what should he do when mothers bring their children for him to hold?

The disciples confused bigness with importance, and shooed the doting parents and their squirmy kids away. But Jesus' idea of what is important often differed from his compatriots' view. "Let the little children come to me, and do not hinder them, for the kingdom of God belongs to such as these."

For many people, adults are important, money is important, power and prestige are important, sensual stimulation is important. Children are either nuisances . . . or expendable tools to help us gain some of these. Even church leaders and Christian parents can forget the priceless value of our little ones.

But the scriptures bring us back to reality. "Sons are a heritage from Yahweh, children a reward from him. Like arrows in the hands of a warrior are sons born in one's youth. Blessed is the man whose quiver is full of them." "I prayed for this child, and Yahweh has granted me what I asked of him." "[F]rom infancy you have known the holy Scriptures, which are able to make you wise for salvation." "Unto us a child is born."

This issue of *Honeycomb* is dedicated to our children. May its articles encourage us to see children the way God sees them, and to love, nurture, and defend them.

# ការជូនដំណឹងពីបណ្ណាធិការ

ត្រីស្តបរិស័ទរវល់រកពេលទំនេរគ្មាន មានរឿងរ៉ាវជាច្រើនដែលត្រូវគិត ហើយរឿងទាំងអស់នោះទៀតសោតសុទ្ធតែសំខាន់ៗ! ការរៀបចំគម្រោងថវិកា ការរៀបចំផែន ការជួបប្រជុំជាមួយមន្ត្រីរដ្ឋាភិបាល ការរៀបចំសេចក្តីអធិប្បាយ ការបង្កើតសិស្ស និងការកែតម្រង់ដល់ក្រុមជំនុំជាដើម ។ ដូច្នេះយើងត្រូវរុញការណាដែលមិនសូវសំខាន់ទុកដោយឡែកសិន ។

ប៉ុន្តែជួនកាលដោយព្រោះតែមមាញឹកក្នុងការទំសម្រេចការងារជាច្រើននោះ យើងបែរទៅជាភ្លេចនូវការងារមួយដែលសំខាន់បំផុតនោះទៅវិញ ។

រឿងនេះគឺវាបានកើតឡើងនៅក្នុងសម័យព្រះយេស៊ូរួចទៅហើយ ។ ព្រះអង្គជួបជាមួយនឹងហ្វូងមនុស្សដែលរង់ចាំស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ មានអ្នកកំពុងព្យាយាមឈ្លបចាប់កំហុសនៅពេលដែលព្រះអង្គមានព្រះបន្ទូល ឯអ្នកខ្វិន និងអ្នកខ្វាក់កំពុងតែព្យាយាមស្រែកដង្ហើយហៅសុំឲ្យព្រះអង្គប្រោសគេឲ្យជា ។ ការទាំងនេះសុទ្ធតែសំខាន់! ចុះតើត្រូវឲ្យព្រះអង្គធ្វើយ៉ាងណា នៅពេលដែលម្តាយៗនាំយកកូនក្មេងមកឲ្យព្រះអង្គលើកពរនោះ?

ពួកសិស្សរបស់ព្រះអង្គច្រឡំធំមែនទែនចំពោះការសំខាន់នោះ ហើយគេបានដេញឪពុកម្តាយ និងកូនរបស់គេចេញពីព្រះយេស៊ូ ។ ប៉ុន្តែព្រះរាជតិះរបស់ព្រះយេស៊ូចំពោះការដែលព្រះអង្គរាប់ថាជាសំខាន់នោះ តែងតែផ្ទុយពីគំនិតរបស់បណ្តារាស្ត្ររបស់ព្រះអង្គ ។ "ចូរឲ្យក្មេងៗចូលមកឯខ្ញុំចុះ កុំឲ្យឃាត់វាឡើយ ដ្បិតនគរស្ថានសួគ៌មានសុទ្ធតែមនុស្សដូចវារាល់គ្នា" ។

ចំពោះមនុស្សជាច្រើនគេរាប់មនុស្សពេញវ័យថាសំខាន់ លុយសំខាន់ អំណាច និងមុខមាត់នោះសំខាន់ ការមានអារម្មណ៍ល្អនៅក្នុងខ្លួន (ត្រេកត្រអាល) នោះគេគិតថាសំខាន់ ។ កុមារគឺអាចជាឧបករណ៍ដែលគេប្រើជាឈ្នាន់ ដើម្បីបំពេញនូវមហិច្ឆតាទាំងអស់នោះ ។ សូម្បីតែអ្នកដឹកនាំក្រុមជំនុំ និងឪពុកម្តាយដែលជឿព្រះហើយនោះ ក៏អាចភ្លេចនូវតម្លៃដែលរកអ្វីប្រៀបផ្ទឹមពុំបានរបស់កូនតូចៗរបស់យើងនោះដែរ ។

ប៉ុន្តែបទគម្ពីរបាននាំយើងឲ្យវិលត្រឡប់មករកធាតុពិតចំពោះការនោះឡើងវិញ ។ "កូនចៅជាមត៌កមកពីព្រះយេហូវ៉ា ជារង្វាន់ដែលមកពីព្រះអង្គ ។ ដូចជាផ្លែព្រួញនៅក្នុងដៃអ្នកចំបាំង គឺជាកូនដែលឯងបង្កើតកាលពីនៅក្មេង ។ មានពរហើយអ្នកណាដែលមានព្រួញពេញក្នុងបំពង់នោះ" ។ "ខ្ញុំបានទូលសុំកូននេះពីព្រះជាអម្ចាស់ ហើយព្រះអង្គក៏ប្រទានកូននេះមកឲ្យខ្ញុំ" ។ "តាំងពីក្មេងមកអ្នកចេះព្រះគម្ពីរបរិសុទ្ធ ដែលធ្វើឲ្យអ្នកមានប្រាជ្ញាសំរាប់ការសង្គ្រោះ" ។ "មានព្រះបុត្រតូចមួយនឹងប្រសូតមកសំរាប់យើង" ។

ព្រឹត្តិបត្រ សំណុំទឹកឃ្មុំ ចេញផ្សាយលេខនេះ គឺយើងសូមឧទ្ទិសយ៉ាងសំខាន់ចំពោះកុមារៗរបស់យើង ។ សូមឲ្យអត្ថបទទាំងនេះជួយជំរុញលើកទឹកចិត្តឲ្យយើងមើលឃើញកុមារៗដូចជាការដែលព្រះជាម្ចាស់ព្រះអង្គទតមើលមកពួកគេដែរ ហើយសូមឲ្យយើងស្រឡាញ់ថែបំប៉ន និងគាំពារគេឲ្យបានល្អផង ។